# សាលាដំបូងរាជធានីភ្នំពេញ
# បទបជ្ជាញស្តីពី
# សន្តតិកម្ម Ⅱ

SHINODA Yoichiro
Attorney at Law (Japan)

# មាតិកា ( សន្តតិកម្មតាមមតកសាសន៍ )

1 សញ្ញាណទូទៅស្តីពីសន្តតិកម្ម ( សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍ )

2 មតកសាសន៍

3 ប្រព័ន្ធនៃភាគបម្រុង (របបដែលការពារសិទ្ធិរបស់សន្តតិជន①)

4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម (របបដែលការពារសិទ្ធិរបស់សន្តតិជន ②)

# 1សញ្ញាណទូទៅស្ដីពីសន្តតិកម្ម
## (1) ករណីសន្តតិកម្មតាមច្បាប់

ការចាប់ផ្ដើមសន្តតិកម្ម=
មរណភាពរបស់មតកជន
(CC1145 I )

ការកំណត់សន្តតិជន=
តើនរណាត្រូវទទួលសន្តតិកម្ម?
(CC ចាប់ពី 1156)

ការកំណត់ចំណែកមត៌ក=
តើការទទួលសន្តតិកម្មធ្វើឡើងដោយរបៀបណា?
(CC ចាប់ពី1156)

ការពិភាក្សាបែងចែកមត៌ក ឬ
<u>ការបែងចែកដោយតុលាការ</u>=
តើបែងចែកដោយរបៀបណា?
(CC ចាប់ពី 1266)

រឿងក្ដីរដ្ឋប្បវេណី
ដែលមិនមែនជា
បណ្ដឹង

※ ក្នុងករណីដែលមានវិវាទអំពីសន្តតិជន ឬ ចំណែកមត៌ក ភាគីអាចកំណត់បញ្ហាទាំងនេះ ដោយប្រើ បណ្ដឹងរដ្ឋប្បវេណី ឬ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។ e.g. <u>បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក</u> <u>បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិសន្តតិកម្ម</u> <u>បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃសុំកូន</u> ជាដើម

# 1 សញ្ញាណទូទៅស្តីពីសន្តតិកម្ម

## (2) ករណីសន្តតិកម្មតាមមតកសាសន៍

ការចាប់ផ្តើមសន្តតិកម្ម=មរណភាព
របស់មតកជន（CC1145 I）



លិខិត
មតកសាសន៍

រឿងក្តី
រដ្ឋប្បវេណីដែល
មិនមែនជា
បណ្តឹង

<u>ការពិនិត្យបញ្ជាក់អំពី</u>
<u>លិខិតមតកសាសន៍</u>
(CC1213)

សន្តតិកម្មដែលបានធ្វើឡើង
តាមរយៈមតកសាសន៍
(ការពិភាក្សាបែងចែកមត៌ក ឬ ការ
បែងចែកមត៌កដោយតុលាការ)

រឿងក្តី
រដ្ឋប្បវេណី

ភាគបម្រុង

→ <u>រឿងក្តីដែល</u>
<u>ទាមទារឲ្យកាត់បន្ថយ</u>
<u>ដើម្បីបង្គ្រប់ភាគបម្រុង</u>

※ អាចមានវិវាទអំពីមោឃភាពនៃមតកសាសន៍

→ <u>បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍</u> (រឿងក្តីរដ្ឋប្បវេណី)

# 2 មតកសាសន៍

## (1) ចំណុចដែលអាចកំណត់ក្នុងមតកសាសន៍

① ការទទួលស្គាល់នូវចំណុចក្រៅពីសន្តតិកម្ម

- ការកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន (CC1068-I)
- ការកំណត់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន (CC1075-I)

② ចំណុចដែលទាក់ទងនឹងសន្តតិកម្ម

- ការផ្ដាច់មត៌កពីជនដែលត្រូវសន្មតថាជាសន្តតិជន និង ការលុបចោលនូវការផ្ដាច់មត៌កនោះ (CC1151-I)
- ការកំណត់ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន (CC1147-II)
- ការកំណត់ចំណែកមត៌ក (CC1182)
- ការលើកលែងយកការទទួលផលប្រយោជន៍ពិសេសត្រឡប់មកវិញ (CC1182)
- ការកំណត់អំពីវិធីបែងចែកមត៌ក និង ការហាមឃាត់ការបែងចែក (CC1183)
- អច្ច័យទានសកល និង អច្ច័យទានមានកំណត់ (CC1199)
- ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ (CC1186)
- វិធីកាត់បន្ថយអច្ច័យទាន (CC1237-IV)

## 2 មតកសាសន៍

## (2) វិធានជាមូលដ្ឋានទាក់ទងនឹងមតកសាសន៍

A. សមត្ថភាពក្នុងការធ្វើមតកសាសន៍

(A) ចាំបាច់ត្រូវតែមានសមត្ថភាពខាងឆន្ទៈជាមុនដើម្បីធ្វើមតកសាសន៍។ (CC1169-I)
សមត្ថភាពខាងឆន្ទៈ ៖ សមត្ថភាពដែលខ្លួនអាចយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន (CC14)

(B) បុគ្គលដែលអាចធ្វើមតកសាសន៍បាន (CC1168)
① បុគ្គលដែលជានីតិជន ៖ បុគ្គលដែលគ្រប់អាយុ១៨ឆ្នាំ ឡើងទៅ (CC17)
② អនីតិជនដែលទទួលបានការប្រកាសអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា ៖ អនីតិជនដែលបានទទួលការប្រកាសឲ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន (CC1095-I) អនីតិជនដែលទទួលបានការប្រកាសអត្តាធីនភាពឲ្យរួចផុតពីអ្នកមានសិទ្ធិអំណាចមេបា (CC21-I) អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ (CC21-II、1095-II)
※ ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភក៏អាចធ្វើមតកសាសន៍បានដែរ (CC1168-II)

## 2 មតកសាសន៍

### (2) វិធានជាមូលដ្ឋានទាក់ទងនឹងមតកសាសន៍

B. ទម្រង់នៃមតកសាសន៍

មតកសាសន៍＝សកម្មភាពជាទម្រង់ដែលមានភាពតឹងរ៉ឹង （CC1170～）

※តាមលទ្ធភាពដែលអាចធ្វើទៅបាន គឺធ្វើឡើងក្នុងគោលបំណងកុំឲ្យកើតមាននូវការសង្ស័យទាក់ទងទៅនឹងមតកសាសន៍ ដោយសារតែមិនអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំនៅពេលដែលអានុភាពនៃមតកសាសន៍បានកើតឡើងទេ (នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព)។

## 2 **មតកសាសន៍**

## (2) **វិធានជាមូលដ្ឋានទាក់ទងនឹងមតកសាសន៍**

B. ទម្រង់នៃមតកសាសន៍

"ទម្រង់ទូទៅនៃមតកសាសន៍"

① មតកសាសន៍ដោយលិខិតយថាភូត (CC1173)
② មតកសាសន៍ដោយលិខិតឯកជន (CC1174)
③ មតកសាសន៍ដោយលិខិតសម្ងាត់ (CC1175)
※ក្នុងករណីដែលជននៅក្រោមអាណាព្យាបាលទូទៅធ្វើមតកសាសន៍ ចាំបាច់ត្រូវគោរពឲ្យត្រូវតាមទម្រង់នៃCC1176។

"ទម្រង់ពិសេសនៃមតកសាសន៍"

④ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (CC1177)
⑤ មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ (CC1178)

# 2 មតកសាសន៍

## (2) វិធានជាមូលដ្ឋានទាក់ទងនឹងមតកសាសន៍

B. ទម្រង់នៃមតកសាសន៍

‶ចំណុចបញ្ហាជុំវិញទម្រង់នៃមតកសាសន៍″

① ប្រសិនបើម្ចាស់បណ្តាំចង់ធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ ប៉ុន្តែ មិនបានបំពេញឲ្យគ្រប់តាមទម្រង់នៃមតកសាសន៍ដោយលិខិតសម្ងាត់ទេ ប៉ុន្តែ ខ្លឹមសារទាំងស្រុងនៃមតកសាសន៍ ព្រមទាំងកាលបរិច្ឆេទសុទ្ធតែបានសរសេរដោយផ្ទាល់ដៃរបស់ម្ចាស់បណ្តាំ តើមតកសាសន៍នេះនឹងមានសុពលភាពដែរឬទេ ?

→ គួរតែយកប្រើជាមតកសាសន៍ដោយលិខិតឯកជន

② ប្រសិនបើម្ចាស់បណ្តាំបានធ្វើមតកសាសន៍ជាលិខិតឯកជន ប៉ុន្តែ ខ្លឹមសារទាំងស្រុងនៃមតកសាសន៍ ត្រូវបានសរសេរជាភាសាអង់គ្លេស តើមតកសាសន៍នេះ នឹងមានសុពលភាពដែរឬទេ ?

→ ដោយសារតែមតកសាសន៍នោះបានបង្ហាញអំពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ដូច្នេះហើយមានសុពលភាព (ភាសាបរទេស អក្សរបរទេសក៏បានដែរ)។

# 2 មតកសាសន៍

## (2) វិធានជាមូលដ្ឋានទាក់ទងនឹងមតកសាសន៍

B. ទម្រង់នៃមតកសាសន៍

"ចំណុចបញ្ហាជុំវិញទម្រង់នៃមតកសាសន៍"

③ តើមតកសាសន៍ដោយលិខិតឯកជនដែលម្ចាស់បណ្តាំបានប្រើកុំព្យូទ័រដើម្បីធ្វើនឹងមានសុពលភាពដែរឬទេ？

→ ដោយសារតែមិនបានបំពេញតាមទម្រង់នៃមតកសាសន៍ដោយលិខិតឯកជនទេ ដូច្នេះហើយនឹងត្រូវមោឃៈ（CC1174 I ）។

④ ក្នុងករណីដែលមតកសាសន៍ដោយលិខិតឯកជនដែលម្ចាស់បណ្តាំបានធ្វើឡើងដោយមិនបានបំពេញតាមទម្រង់ទេ ហើយត្រូវគេវិនិច្ឆ័យថា មតកសាសន៍នោះត្រូវមោឃៈ តើមកតសាសន៍នោះអាចយកមកប្រើជាប្រទានកម្មដោយមូលហេតុមរណភាពវិញបានទេ？

→ ដោយសារតែមាត្រាស្តីពីប្រទានកម្មដោយមូលហេតុមរណភាព មិនយកទម្រង់នៃមតកសាសន៍មកអនុវត្តដូចគ្នានោះទេ ដូច្នេះ អាចយកមតកសាសន៍ខាងលើមកប្រើជាប្រទានកម្មដោយមូលហេតុមរណភាពបាន។

## 2 មតកសាសន៍

### (2) វិធានជាមូលដ្ឋានទាក់ទងនឹងមតកសាសន៍

C. ការលុបចោលនូវមតកសាសន៍

មតកសាសន៍ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព （CC1194-I） ប៉ុន្តែ នៅចន្លោះពេលនោះ ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ពេលណាក៏បាន។

〝វិធីនៃការលុបចោលនូវមតកសាសន៍〟

① ការលុបចោលដោយមតកសាសន៍ （CC1188、1189-I）

② ការលុបចោលដោយមតកសាសន៍ដែលមានភាពផ្ទុយ （CC1188、11891-II）

③ ការលុបចោលដោយសកម្មភាពដែលមានភាពផ្ទុយ （CC1188、1190）

④ ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ជាអាទិ៍ （CC1188、1191）

# 2 មតកសាសន៍

## (3) ការពិនិត្យបញ្ជាក់មតកសាសន៍

រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

ចំពោះមតកសាសន៍ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត អ្នកដែលបានរក្សាទុក ឬ អ្នកដែលបានរកឃើញនូវលិខិតមតកសាសន៍ត្រូវតែដាក់ពាក្យសុំឲ្យពិនិត្យបញ្ជាក់នៅតុលាការ ។

※ ចំពោះពាក្យសុំឲ្យពិនិត្យបញ្ជាក់លើលិខិតមតកសាសន៍ គឺមិនត្រូវការវត្តមានភាគីម្ខាងទៀតទេ

① គោលគំនិតនៃការពិនិត្យបញ្ជាក់

ការពិនិត្យបញ្ជាក់ គឺជានីតិវិធីដើម្បីការពារនូវការក្លែងបន្លំ ឬ លាក់ទុកនូវលិខិតមតកសាសន៍ ហើយជានីតិវិធីដើម្បីរក្សាទុកនូវភស្តុតាងតាមរយៈការបញ្ជាក់អំពីស្ថានភាពជាក់ស្ដែងនៃលិខិតមតកសាសន៍។

② ការបើកលិខិតមតកសាសន៍ដែលត្រូវបានបិទដោយប្រថាប់ត្រាដោយមិនឆ្លងកាត់នូវការពិនិត្យបញ្ជាក់

ពិន័យស៊ីវិលជាប្រាក់មិនលើសពី1,000,000 (មួយលាន)រៀល (CC1213-IV) ។

មតកសាសន៍នឹងមិនត្រូវមោឃៈទេ (CC1213-V)

# 2 មតកសាសន៍

## (3) ការពិនិត្យបញ្ជាក់មតកសាសន៍

រឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

"យោង" ការបញ្ជាក់មតកសាសន៍ (CC1177-II、-III)

- ប្រសិនបើជាមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ត្រូវតែទទួលបានការបញ្ជាក់មតកសាសន៍នៅតុលាការ។
- តុលាការត្រូវតែវិនិច្ឆ័យថា តើមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ត្រឹមត្រូវតាមឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំដែរឬទេ?
- ចំពោះមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ក្រោយពីទទួលបានការបញ្ជាក់នៅតុលាការរួចហើយ ចាំបាច់ត្រូវតែធ្វើនីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ (ដោយសារតែគោលបំណងនៃការបញ្ជាក់មតកសាសន៍ (CC1177-II、-III) និង ការពិនិត្យបញ្ជាក់មតកសាសន៍ (CC1213) មានភាពខុសគ្នា)។

## 2 មតកសាសន៍

### (4) ការប្រតិបត្តិមតកសាសន៍

### A. អត្ថន័យនៃការប្រតិបត្តិមតកសាសន៍

គោលបំណងនៃមតកសាសន៍

- ធ្វើឲ្យអានុភាពកើតឡើងតាមមតកសាសន៍នោះ

  e.g. ការកំណត់អំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការកំណត់អំពីចំណែកមត៌ក និង ការកំណត់អំពីវិធីបែងចែកមត៌កជាអាទិ៍

- ដើម្បីឲ្យខ្លឹមសារក្នុងមតកសាសន៍អាចអនុវត្តបាន ចាំបាច់ត្រូវធ្វើការប្រតិបត្តិ

  e.g. ការទទួលស្គាល់ (ការដាក់ពាក្យសុំ) 、ការផ្តាច់សន្តតិជន (ចាំបាច់ត្រូវមានការទាមទារទៅតុលាការ) 、អច្ច័យទាន (ការប្រគល់វត្ថុ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលវត្ថុ) ជាអាទិ៍

※ ការទទួលស្គាល់ និង ការផ្តាច់សន្តតិជន ចាំបាច់ត្រូវតែមានអ្នកប្រតិបត្តិមតកសាសន៍។

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

### B. អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍

- ម្ចាស់បណ្តាំជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍នៅក្នុងមតកសាសន៍ (CC1186)
- តុលាការនឹងជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍តាមការទាមទាររបស់អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ (CC1218)

រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

※ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និងជនធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ (CC1217) ។

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

C. សិទ្ធិអំណាច និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍

① ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ (CC1219)

② សិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍។ (CC1220)

→ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឲ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។ (CC1221-I)

→ ប្រសិនបើសន្តតិជនបានចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឲ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍ សកម្មភាពនោះនឹងត្រូវមោឃៈ (CC1221-II)

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

C. សិទ្ធិអំណាច និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍

“ឧទាហរណ៍លម្អិត”

ប្អូនប្រុសB

មតកជន ឪពុកX

កូនA



ឲ្យប្អូនប្រុសB ដែលរស់នៅជាមួយ X ទទួលសន្តតិកម្មទាំងអស់នូវ អចលនវត្ថុទាំងអស់ដែលជាកម្មសិទ្ធិរបស់X។
កំណត់ថា Y គឺជាអ្នកប្រតិបត្តិមតកសាសន៍។

មតកសាសន៍ដោយលិខិតយថាភូត



ដីនិង អាគារL

ក្រោយពី X បានទទួលមរណភាព A បានចុះបញ្ជីនូវដី និង អាគារ L ដោយដាក់ឈ្មោះរបស់ A ហើយក្រោយមក បានលក់ទៅឲ្យតតិយជន D និង បានចុះបញ្ជីផ្ទេរកម្មសិទ្ធិរួចរាល់ ដោយមិនបានដឹងថាមានមតកសាសាន៍ទេ។

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

### C. សិទ្ធិអំណាច និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍

“ឧទាហរណ៍លម្អិត”



ដើមចោទ

អ្នកប្រតិបត្តិមតកសាសន៍ Y របស់មតកជនX

ការទាមទារឲ្យចុះបញ្ជីលុបចោល

អំពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិL



ចុងចម្លើយD



ចុងចម្លើយA

※ ស្តីអំពីសកម្មភាពដែលទាក់ទងនឹងការប្រតិបត្តិមតកសាសន៍ ជាគោលការណ៍ គឺមានតែអ្នកប្រតិបត្តិមតកសាសន៍តែប៉ុណ្ណោះដែលមានលក្ខណៈគ្រប់គ្រាន់ជាភាគីក្នុងបណ្តឹង។

※ ប៉ុន្តែ ចំពោះការទាមទារឲ្យលុបការចុះបញ្ជីដែលមោឃៈដែលត្រូវបានធ្វើទៅឲ្យសន្តតិជនម្នាក់ ឬ តតិយជន នូវកម្មវត្ថុនៃអច្ច័យទានដូចមានក្នុងអង្គហេតុខាងលើនេះ គឺ អ្នកប្រតិបត្តិមតកសាសន៍ ឬ អច្ច័យលាភី ឬ  អាចរួមគ្នាធ្វើជាភាគីក្នុងនាមជាកម្មសិទ្ធិករនៃដីនោះ។

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

C. សិទ្ធិអំណាច និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍

“ឧទាហរណ៍លម្អិត”







ផ្អែកតាមក្រមរដ្ឋប្បវេណី មាត្រា 134 កថាខណ្ឌទី1 តើD ដែលជាអ្នកបានចុះបញ្ជី អាចតតាំងអំពីកម្មសិទ្ធិលើL ចំពោះ B បានដែរឬទេ ?

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

C. សិទ្ធិអំណាច និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍

“ឧទាហរណ៍លម្អិត”







ក្នុងករណីដែលមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌កបានឡើយ។ ប្រសិនបើសន្តតិជនបានចាត់ចែង ការចាត់ចែងនោះនឹងត្រូវមោឃៈ（CC1221-II）។

→ ទោះបីជា B គ្មានការចុះបញ្ជីក៏ដោយ ក៏អាចអះអាងអំពីកម្មសិទ្ធិចំពោះ D បានដែរ។

# 2 មតកសាសន៍

## (4) ការប្រតិបត្តិមតកសាសន៍

C. សិទ្ធិអំណាច និង ករណីយកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ “ឧទាហរណ៍លម្អិត”

រឿងក្ដី
រដ្ឋប្បវេណី

ការទាមទារឲ្យចុះបញ្ជីលុបចោល
អំពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិL





ដើមចោទ
អ្នកប្រតិបត្តិមតកសាសន៍ Y របស់មតកជនX

(ឧទាហរណ៍នៃសេចក្ដីសម្រេចបញ្ចប់)

បង្គាប់ឲ្យចុងចម្លើយA និង D ធ្វើនីតិវិធីចុះបញ្ជីលុបចោលស្ដីពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើ L ( ពត៌មានដែលអំពីកំណត់កម្មវត្ថុ ) ដែលមានលេខចុះបញ្ជី ............. ឲ្យទៅដើមចោទ Y ដែលជាអ្នកប្រតិបត្តិមតកសាសន៍របស់មតកជនX ដោយមូលហេតុមោឃភាព។

# 2 មតកសាសន៍

## (5) បញ្ហាទាក់ទងនឹងអច្ច័យទាន

“ចំណុចដែលមានបញ្ហា”






មតកសាសន៍របស់X

(ករណីសិក្សា1) “ឲ្យBទទួលសន្តតិកម្មនូវចំណែកពាក់កណ្ដាលនៃមត៌ក”

(ករណីសិក្សា2) “ឲ្យ C ទទួលសន្តតិកម្មនូវអចលនវត្ថុL”

ចំណុចដែលមានបញ្ហាគឺពាក្យថា “<u>ឲ្យទទួលសន្តតិកម្ម</u>” ដោយសារតែពាក្យនេះមិនមានភាពច្បាស់លាស់ថា តើជាអច្ច័យទាន ឬ ការកំណត់នូវចំណែកមត៌ក?

# 2 មរតកសាសន៍

## (5) បញ្ហាទាក់ទងនឹងអច្ច័យទាន

“ស្តីអំពី ករណីសិក្សា1”

“ឲ្យBទទួលសន្តតិកម្មនូវចំណែកពាក់កណ្តាលនៃមត៌ក”

→អច្ច័យទានសកល（CC1199）？　ការកំណត់ចំណែកមត៌ក（CC182）？

ប៉ុន្តែ ក្នុងករណីសិក្សានេះ ជាចុងក្រោយ សន្តតិជននឹងត្រូវទទួលនូវចំណែកមត៌ក ដែលBមានចំណែក១ភាគ២លើមត៌ក ដូច្នេះហើយ ពុំមានអ្វីខុសប្លែកគ្នាខ្លាំងទេ។



## 2 មតកសាសន៍

## (5) បញ្ហាទាក់ទងនឹងអច្ច័យទាន

"ករណីសិក្សា 2"

"ឲ្យ C ទទួលសន្តតិកម្មនូវអចលនវត្ថុL"

→ អច្ច័យទានមានកំណត់ (CC1199) ? ការកំណត់នូវវិធីបែងចែក (CC1183) ?

- ប្រសិនបើយល់ឃើញថាជា អច្ច័យទានមានកំណត់ នោះអានុភាពនៃមតកសាសន៍នឹងកើតមានឡើងនៅពេលដែលXបានទទួលមរណភាព (CC1194-I) ហើយកម្មសិទ្ធិលើអចលនវត្ថុL នឹងផ្ទេរពី X ទៅ C។




- ប្រសិនបើយល់ឃើញថាជា ការកំណត់នូវវិធីបែងចែក នោះនាពេលអនាគត ក្រោយពីបានឆ្លងកាត់ការបែងចែកមត៌ករួច ហើយ កម្មសិទ្ធិលើអចលនវត្ថុL ច្បាស់ជាត្រូវផ្ទេរពី X ទៅ C។



## 2 មតកសាសន៍

### (5) បញ្ហាទាក់ទងនឹងអច្ច័យទាន

"អំពីករណីសិក្សា 2"

"ឲ្យ C ទទួលសន្តតិកម្មនូវអចលនវត្ថុL"

→ សន្មត (CC1185-I) ថាជា ការកំណត់នូវវិធីបែងចែក (CC1183)

※ ប្រសិនបើម្ចាស់បណ្តាំពិតជាចង់ធ្វើអច្ច័យទានមែន នោះច្បាស់ជាសរសេរយ៉ាងច្បាស់អំពីអច្ច័យទាន។ ការដែលសរសេរថា "ឲ្យទទួលសន្តតិកម្ម" មិនអាចនិយាយបានច្បាស់ថា ជាអច្ច័យទាននោះ ដូច្នេះហើយ ការសរសេរបែបនេះត្រូវសន្មតថាជា ការកំណត់អំពីវិធីបែងចែក ទើបត្រូវទៅនឹងឆន្ទៈរបស់ម្ចាស់បណ្តាំ។

※ ដោយសារតែ "អចលវត្ថុ L ត្រូវធ្វើប្រទានកម្មទៅ C" គឺបញ្ជាក់ច្បាស់ថាជាអច្ច័យទាន ដូច្នេះ ហើយនឹងត្រូវចាត់ចែងជាអច្ច័យទាន។

# 2 មតកសាសន៍

## (5) បញ្ហាទាក់ទងនឹងអច្ច័យទាន

"អំពីករណីសិក្សា 2"

"ឲ្យ C ទទួលសន្តតិកម្មនូវអចលនវត្ថុ L"

→ ប៉ុន្តែ អានុភាពនៃការផ្ទេរកម្មសិទ្ធិពី X ទៅ C នឹងកើតមានឡើងនៅពេលដែលមតកជន X បានទទួលមរណភាព (CC1195-I)

X ទទួលមរណភាព　　ការផ្ទេរអចលនវត្ថុ L



※ចំពោះអចលនវត្ថុ L ដែលជាទ្រព្យសម្បត្តិជាក់លាក់ គឺ C ជាអ្នកទទួលសន្តតិកម្ម ដោយហេតុថា ចំណុចនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងមតកសាសន៍របស់ X ហើយនៅក្នុងមតកសាសន៍នេះ ក៏មិនបានលើកឡើងអំពីសហសន្តតិជនផ្សេងទៀតដែរ ហេតុនេះហើយមិនអាចធ្វើការបែងចែកទ្រព្យសម្បត្តិដោយការព្រមព្រៀង ឬ ការបែងចែកដោយតុលាការឲ្យខុសពីមតកសាសន៍នេះបានទេ ។

# 2 មតកសាសន៍

## (6) បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍

រឿងក្ដីរដ្ឋប្បវេណី

“ឧទាហរណ៍នៃបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍”




“ឲ្យកូនស្រីច្បង B ទទួលសន្តតិកម្មនូវមត៌កទាំងអស់”



មតកសាសន៍
ដោយលិខិត
ឯកជនរបស់X



A

នៅពេលដែល X បានធ្វើមតកសាសន៍ដោយលិខិតឯកជន Xមានជំងឺចាស់វង្វេងវង្វាន់ (Senile dementia) ហើយមិនមានសមត្ថភាពក្នុងការធ្វើមតកសាសន៍ទេ ហេតុនេះមតកសាសន៍ត្រូវមោឃៈ។

រឿងក្តីរដ្ឋប្បវេណី

# 2 មតកសាសន៍

## (6) បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍

“ឧទាហរណ៍នៃបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍”

បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍



ដើមចោទ A



ចុងចម្លើយ B

# 2 មតកសាសន៍



## (6) បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍

“ការបង្កើតនូវការអះអាងនិងបញ្ជាក់ភស្តុតាងស្តីពីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍”



ដើមចោទ A

(មូលហេតុនៃការទាមទារ)

① ការអះអាងរបស់ចុងចម្លើយអំពីអត្ថិភាពនៃមតកសាសន៍

→ ចុងចម្លើយ B អះអាងថា នៅថ្ងៃទី.....ខែ.....ឆ្នាំ............ X បានធ្វើមតកសាសន៍ដោយលិខិតឯកជនថា ឲ្យកូនស្រីច្បងBទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិទាំងអស់របស់X។

② ការទទួលមរណភាពរបស់ម្ចាស់បណ្តាំ

→ X បានទទួលមរណភាពនៅថ្ងៃទី..... ខែ.....ឆ្នាំ.........។

③ ម្ចាស់បណ្តាំមានកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍នៅពេលដែលបានទទួលមរណភាព

→ (បានអះអាងក្នុងចំណុច①រួចហើយ)

④ ដើមចោទគឺជាសន្តតិជនរបស់ម្ចាស់បណ្តាំ ឬ ជាអ្នកទទួលបន្តពីម្ចាស់បណ្តាំ

→ ដើមចោទA គឺជាសន្តតិជនរបស់ម្ចាស់បណ្តាំX។

## 2 មតកសាសន៍

រឿងក្តីរដ្ឋប្បវេណី

## (6) បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍

"ការបង្កើតនូវការអះអាងនិងបញ្ជាក់ភស្តុតាងស្តីពីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍"



ចុងចម្លើយ B

(ការតវ៉ា : លក្ខខណ្ឌនៃការបង្កើតលិខិតមតកសាសន៍បានធ្វើឡើងដោយមានភាពមត្រឹមត្រូវ)

① ម្ចាស់បណ្តាំបានសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែ ហើយបានចុះហត្ថលេខាលើមតកសាសន៍នោះ (CC1174-I)

→ មតកសាសន៍ដោយលិខិតឯកជនចុះថ្ងៃទី.....ខែ....ឆ្នាំ.......ដែលមានសរសេរក្នុងតារាងឧបសម្ព័ន្ធ គឺជាលិខិតដែល X បានសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែ ហើយបានចុះហត្ថលេខា។

※ ចំពោះលក្ខខណ្ឌក្នុងការបង្កើតមតកសាសន៍ដែលត្រឹមត្រូវ គឺភាគីដែលអះអាងថាមតកសាសន៍មានសុពលភាព ជាអ្នកមានបន្ទុកក្នុងការអះអាងនិងបញ្ជាក់ភស្តុតាង។

# 2 មតកសាសន៍



## (6) បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍

"ការបង្កើតនូវការអះអាងនិងបញ្ជាក់ភស្តុតាងស្តីពីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍"



ដើមចោទA

(ការតវ៉ាតប : មូលហេតុមោឃភាពនៃមតកសាសន៍

① គ្មានសមត្ថភាពក្នុងការធ្វើមតកសាសន៍នៅពេលដែលធ្វើមតកសាសន៍ (CC1169)

→ នៅថ្ងៃទី....ខែ.....ឆ្នាំ........ X មានជំងឺចាស់វង្វេងវង្វាន់(Senile dementia) បាត់ទៅ ហើយ ដូច្នេះ មិនមានសមត្ថភាពក្នុងការធ្វើមតកសាសន៍ទេ។

※ មូលហេតុមោឃភាពផ្សេងទៀត

a. ការលុបចោលដោយសារការបង្ហាញឆន្ទៈមានវិការៈ (ចាប់ពីCC345) 、មោឃភាពដោយសារបបនីយផ្លូវចិត្ត ឬ ការបង្ហាញឆន្ទៈមិនពិត (CC352 ឬ 353) 、មោឃភាពដោយសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ (CC354) ជាអាទិ៍

b. ការទទួលមរណភាពរបស់អច្ច័យលាភីនៅមុនពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព (CC1200)

c. មូលហេតុដែលនាំឲ្យខ្វះលក្ខណៈសម្បត្តិជាសាក្សីនៅពេលធ្វើមតកសាសន៍ ឬ អ្នកសង្កេតការណ៍ (CC1172)

d. ការកម្រិតក្នុងការធ្វើមតកសាសន៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ (CC1176)

# 2 មតកសាសន៍

រឿងក្តីរដ្ឋប្បវេណី

## (6) បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍

"ការបង្កើតនូវការអះអាងនិងបញ្ជាក់ភស្តុតាងស្តីពីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍"



ដើមចោទA

បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍



(ឧទាហរណ៍នៃខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់)

បញ្ជាក់ថា មតកសាសន៍ដោយលិខិតឯកជនដែលXបានធ្វើនៅថ្ងៃទី....ខែ...ឆ្នាំ......ដែលមានក្នុងតារាងឧបសម្ព័ន្ធ គឺមោឃៈ។

## 3 ប្រព័ន្ធនៃភាគបម្រុង

### (1) អត្ថន័យអំពីប្រព័ន្ធនៃភាគបម្រុង

គឺជារបបដែលធ្វើការការពារដល់សន្តតិជនដែលកំណត់ដោយច្បាប់ត្រឹមទំហំជាក់លាក់ ដោយធ្វើការបដិសេធនូវអានុភាពនៃប្រទានកម្ម ឬ អច្ច័យទានជាអាទិ៍ ដែលបានធ្វើដោយមតកជន ហើយបង្វែរនូវទ្រព្យសម្បត្តិ និង ផលប្រយោជន៍ទាំងអស់នោះមកឲ្យសន្តតិជនដែលកំណត់ដោយច្បាប់

↓

របបដែលការពារសិទ្ធិរបស់សន្តតិជន①

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

A. អ្នកមានសិទ្ធិលើភាគបម្រុង ៖ សហព័ទ្ធ កូន （សន្តតិជនជំនួស） ឪពុកម្តាយ ឬ ជីដូនជីតា （CC1230）



# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

### B. ដំណាក់កាលនៃការគណនាភាគបម្រុង

a.(A) គណនាសមាមាត្រនៃភាគបម្រុងរបស់សន្តតិជន （CC1230）

(B) គណនាទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង （CC1231）

(C) គណនានូវអត្ថិភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង និង ចំនួនទឹកប្រាក់ដែលបានបំពាន （CC1234）

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

### B. ដំណាក់កាលនៃការគណនាភាគបម្រុង

(A) គណនាសមាមាត្រនៃភាគបម្រុងរបស់សន្តតិជន (CC1230)

①បង្ហាញឲ្យច្បាស់នូវសមាមាត្រនៃភាគបម្រុងរបស់សន្តតិជនទាំងអស់ចំពោះមត៌កទាំងអស់ (CC1230-I) ។



②គណនានូវសមាមាត្រភាគបម្រុងរបស់សន្តតិជនម្នាក់ៗ (CC1230-II、1162ជាអាទិ៍) ។
※ ចំពោះភាគបម្រុងរបស់សន្តតិជនទាំងអស់ត្រូវសម្រេចថា តើត្រូវបែងចែកបែបណាក្នុងចំណោមសន្តតិជន？

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

(B) គណនាទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង （CC1231）

①ទ្រព្យសកម្មដែលមាននៅពេលចាប់ផ្តើមសន្តិកម្ម **+** ②ប្រទានកម្មដែលត្រូវបូកបន្ថែមជាអាទិ៍ **−** ③កាតព្វកិច្ច **=** ④ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

## 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនាទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

(B) គណនាទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង（CC1231）

② ទ្រព្យដែលត្រូវបូកបន្ថែម

a. ការទទួលផលប្រយោជន៍ពិសេសរបស់សន្តតិជន（CC1231-I）

b. ប្រទានកម្មដែលមតកជនបានធ្វើក្នុងអំឡុងពេល1ឆ្នាំនៅមុនចាប់ផ្តើមសន្តតិកម្ម（CC1232-I①）

※ ប៉ុន្តែ ប្រទានកម្មដែលបានធ្វើឡើង "ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង" ទោះបីជាមុន1ឆ្នាំក៏ដោយ ក៏ចាំបាច់ត្រូវតែបូកបញ្ចូលដែរ។

c. លើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ（CC1232-II）

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

(C) គណនានូវអត្ថិភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង និង ចំនួនទឹកប្រាក់ដែលបានបំពាន (CC1234)

a.អត្ថិភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង

ទឹកប្រាក់នៃភាគបម្រុង > ①ចំនួនទឹកប្រាក់នៃទ្រព្យដែលទទួលបានដោយសារសន្តតិកម្ម + ②ចំនួនទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេស − ③ចំនួនទឹកប្រាក់នៃកាតព្វកិច្ចសន្តតិកម្ម

→ មានការបំពានភាគបម្រុង

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ជំណាក់កាលនៃការគណនាភាគបម្រុង

(C) គណនានូវអត្ថិភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង និង ចំនួនទឹកប្រាក់ដែលបានបំពាន （CC1234）

b. ការគណនាទឹកប្រាក់ដែលបានបំពាន

ទឹកប្រាក់នៃភាគបម្រុង − ①ចំនួនទឹកប្រាក់នៃទ្រព្យដែលទទួលបានដោយសារសន្តតិកម្ម − ②ចំនួនទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេស ＋ ③ចំនួនទឹកប្រាក់នៃកាតព្វកិច្ចសន្តតិកម្ម

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនាលទ្ធទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

"ឧទាហរណ៍លម្អិត"

នៅពេល A ទទួលមរណភាព មានប្រពន្ធ B និង កូនC ដែលជាសន្តតិជន។ មុនពេលស្លាប់ A បានធ្វើប្រទានកម្មនូវអចលនវត្ថុ L ដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយគិតជាប្រាក់ស្មើនឹង500,000ដុល្លារ ឲ្យទៅសង្ឃរាD ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះ។ នៅពេលដែល A ស្លាប់ មិនឃើញមានទ្រព្យសម្បត្តិអ្វីទេ គឺបន្សល់ទុកតែប្រាក់កម្ចីចំនួន100,000 ដុល្លារ។

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

“ករណីសិក្សាលម្អិត”




អចលនវត្ថុ L ដែលមានតម្លៃស្មើនឹង500,000$

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

### B. ដំណាក់កាលនៃការគណនាភាគបម្រុង

(A) គណនាសមាមាត្រនៃភាគបម្រុង（CC1230)

① សមាមាត្រនៃភាគបម្រុងរបស់សន្តតិជនទាំងអស់ធៀបនឹងមត៌កទាំងអស់ស្មើនឹង1/2
（CC1230-I②）។



② សមាមាត្រនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ គឺ៖

សហព័ទ្ធB：1/4

កូនC：1/4

（CC1230-II、1162①）

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

(B) ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង（CC1231）

① ទ្រព្យសកម្មនៅពេលចាប់ផ្តើមបើកសន្តិកម្ម＝0$

② ទ្រព្យដែលត្រូវបូកបន្ថែម＝500,000$（ប្រទានកម្មឲ្យទៅ D）

③ ដកកាតព្វកិច្ច＝100,000$（ប្រាក់កម្ចីរបស់A）

④ ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង＝400,000$（500,000$ - 100,000$）

①ទ្រព្យសកម្មនៅពេលចាប់ផ្តើមបើកសន្តិកម្ម ＋ ②ប្រទានកម្មដែលត្រូវបូកបន្ថែមជាអាទិ៍ － ③កាតព្វកិច្ច ＝ ④ ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

### B. ដំណាក់កាលនៃការគណនាភាគបម្រុង

(B) ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង（CC1231）

ទ្រព្យដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង ＝400,000$

ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនទាំងអស់ធៀបនឹងមត៌កទាំងអស់＝200,000$（400,000$ X 1/2）



ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗ＝
សហព័ទ្ធ：100,000$、កូន C：100,000$（400,000$ X 1/4）

# 3 ប្រព័ន្ធនៃភាគបម្រុង

## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង

(C) គណនានូវអត្ថិភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង និង ចំនួនទឹកប្រាក់ដែលបានបំពាន(CC1234)

① ចំនួនទឹកប្រាក់នៃទ្រព្យដែលទទួលបានដោយសារសន្តតិកម្ម ＝0$

② តម្លៃនៃការទទួលផលប្រយោជន៍ពិសេស＝0$

③ តម្លៃនៃកាតព្វកិច្ចសន្តតិកម្ម＝សហព័ទ្ធ B：50,000$、 កូន C：50,000$
（100,000$ （ប្រាក់កម្ចីរបស់មតកជន） X 1/2）

ចំនួនទឹកប្រាក់នៃភាគបម្រុង > ① ចំនួនទឹកប្រាក់នៃទ្រព្យដែលទទួលបានដោយសារសន្តតិកម្ម + ② តម្លៃនៃការទទួលផលប្រយោជន៍ពិសេស − ③ តម្លៃនៃកាតព្វកិច្ចសន្តតិកម្ម

# 3 ប្រព័ន្ធនៃភាគបម្រុង
## (2) ការគណនានូវទឹកប្រាក់នៃភាគបម្រុង និង ទឹកប្រាក់ដែលបានបំពាន

B. ដំណាក់កាលនៃការគណនាភាគបម្រុង
(C) គណនានូវអត្ថិភាព ឬ នត្ថិភាពនៃការបំពានភាគបម្រុង និង ចំនួនទឹកប្រាក់ដែលបានបំពាន(CC1234)

ចំនួនទឹកប្រាក់ដែលបានបំពាន = សហព័ទ្ធB : 150,000$、 កូនC : 150,000$
（100,000$ （ចំនួនទឹកប្រាក់ដែលបានបំពាន） - 0$ (①) - 0$ (②) + 50,000$ （③） ）

→ B និង C អាចទាមទារចំពោះ Dឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក្នុងម្នាក់ៗចំនួន 150,000$។

ចំនួនទឹកប្រាក់នៃភាគបម្រុង − ① ចំនួនទឹកប្រាក់នៃទ្រព្យដែលទទួលបានដោយសារសន្តតិកម្ម − ② តម្លៃនៃការទទួលផលប្រយោជន៍ពិសេស + ③ តម្លៃនៃកាតព្វកិច្ចសន្តតិកម្ម

# 3 ប្រព័ន្ធនៃភាគបម្រុង

## (3) ការអនុវត្តនូវសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

A. កម្មវត្ថុនៃការកាត់បន្ថយ（CC1233、1235）

① អច្ច័យទាន
② ការកំណត់ចំណែកមត៌កតាមមតកសាសន៍
③ ប្រទានកម្ម (ប្រទានកម្មដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេល1ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម)
④ ប្រទានកម្ម (ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង)
⑤ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ
⑥ ការទទួលផលប្រយោជន៍ពិសេស

# 3 ប្រព័ន្ធនៃភាគបម្រុង

## (3) ការអនុវត្តនូវសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

B. លំដាប់នៃការកាត់បន្ថយ（CC1236、1237、1238）

① អច្ច័យទាន និង ការកំណត់ចំណែកមត៌កតាមមតកសាសន៍ចំពោះសន្តតិជន
→ អច្ច័យទាន និង ការកំណត់ចំណែកមត៌កត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ（CC1237-II）
② អច្ច័យទានចំពោះបុគ្គលផ្សេងពីសន្តតិជន
→ អច្ច័យទានត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់វត្ថុនោះ（CC1237-II）
③ ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស
→ ត្រូវធ្វើការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលត្រូវបានធ្វើក្រោយគេជាបន្តបន្ទាប់（CC1238-I）

# 3 ប្រព័ន្ធនៃភាគបម្រុង

## (3) ការអនុវត្តនូវសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

C.  ការអនុវត្តនូវសិទ្ធិទាមទារឲ្យកាត់បន្ថយ

សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងត្រូវធ្វើឡើងផ្អែកតាមការបង្ហាញឆន្ទៈ ដោយធ្វើការកំណត់នូវកម្មវត្ថុនៃការកាត់បន្ថយចំពោះភាគីម្ខាងទៀត។

ការបង្ហាញឆន្ទៈនេះអាចធ្វើឡើងនៅក្រៅតុលាការក៏បាន ឬ អាចធ្វើឡើងដោយការបង្ហាញឆន្ទៈដោយតុណ្ហីភាពក៏បាន។



អ្នកមានសិទ្ធិលើភាគបម្រុងA

មតកជនបានសម្រេចថាឲ្យទ្រព្យសម្បត្តិទាំងអស់ឲ្យទៅអ្នកតាមរយៈលិខិតមតកសាសន៍ចុះថ្ងៃទី.....ខែ....ឆ្នាំ.......។ លិខិតមតកសាសន៍នេះ គឺបំពាននូវភាគបម្រុងរបស់ខ្ញុំ ។ ហេតុនេះហើយ ខ្ញុំទាមទារឲ្យអ្នកកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។



ភាគីម្ខាងទៀតB

# 3 ប្រព័ន្ធនៃភាគបម្រុង

## (4) លក្ខណៈ និង អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

A. លក្ខណៈតាមផ្លូវច្បាប់នៃសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ＝សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត



# 3 ប្រព័ន្ធនៃភាគបម្រុង

## (4) លក្ខណៈ និង អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

B. អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

សិទ្ធិទាមទារឲ្យប្រគល់វត្ថុជាក់ស្តែង（គោលការណ៍）← សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ＝សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត

- តម្លៃនៃការសង
  ① ក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើអនុប្បទាន（CC1243）
  ← ករណីដែលប្រគល់វត្ថុជាក់ស្តែងមិនអាចធ្វើបាន
  ② តម្លៃនៃការសងជំនួសឲ្យការប្រគល់ជាវត្ថុជាក់ស្តែង（CC1244）
  ← ជាបញ្ញត្តិដែលលើកឡើងថា អាចប្រគល់វត្ថុជាក់ស្តែងបាន ប៉ុន្តែត្រូវពិចារណាអំពីផលប្រយោជន៍របស់ភាគីម្ខាងទៀត។

# 3 ប្រព័ន្ធនៃភាគបម្រុង

## (4) លក្ខណៈ និង អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

B. អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

① ក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើអនុប្បទាន (CC1243)



# 3 ប្រព័ន្ធនៃភាគបម្រុង

## (4) លក្ខណៈ និង អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

B. អានុភាពនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ

② តម្លៃនៃការសងជំនួសឲ្យការប្រគល់ជាវត្ថុជាក់ស្តែង (CC1244)

ការបង្ហាញឆន្ទៈអំពីការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង



អ្នកមានសិទ្ធិលើភាគបម្រុងA

ករណីយកិច្ចប្រគល់វត្ថុជាក់ស្តែងវិញ





ភាគីម្ខាងទៀតB



កម្មវត្ថុ

※ ប្រសិនបើBបានសងនូវតម្លៃនៃកម្មវត្ថុរបស់ប្រទានកម្ម នោះ ករណីយកិច្ចប្រគល់វត្ថុជាក់ស្តែងដែលBមានចំពោះAនឹងត្រូវរលត់។

## 3 ប្រព័ន្ធនៃភាគបម្រុង

## (5) អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងជាអាទិ៍

A. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយ (CC1245)

① 1 ឆ្នាំគិតចាប់ពីពេលដែលបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង ប្រទានកម្ម ឬ អច្ច័យទានជាអាទិ៍ដែលត្រូវកាត់បន្ថយ

② 5ឆ្នាំគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម



# 3 ប្រព័ន្ធនៃភាគបម្រុង

## (5) អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងជាអាទិ៍

B. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យកាត់បន្ថយ

សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ＝សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត



ការបង្ហាញឆន្ទៈអំពីការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង



អ្នកមានសិទ្ធិលើភាគបម្រុងA

ករណីយកិច្ចដែលBត្រូវប្រគល់ឲ្យទៅAវិញ

＝សិទ្ធិទាមទារឲ្យប្រគល់វិញដែលAមានចំពោះB

ភាគីម្ខាងទៀតB

※ដោយសារតែសិទ្ធិទាមទារឲ្យប្រគល់វិញដែលA មានចំពោះB  គឺជាសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស (សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ) ដូច្នេះហើយ សិទ្ធិទាមទារឲ្យប្រគល់វិញនេះ ពុំមានអាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ។ ប៉ុន្តែ ក៏មានការយល់ឃើញផ្ទុយពីនេះដែរ។

# 4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម

“ករណីសិក្សា”

មត៌ក : មានតែអចលនវត្ថុLប៉ុណ្ណោះ






B

ដោយសារតែសន្តតិជនរួម មាន B C និងD ដូច្នេះ ហើយទើប C និង D មិន យល់ព្រមតាមការបែង ចែកមត៌កដែលបានធ្វើ ឡើងដោយចិត្តឯងទេ។ ពួកគេចង់ទទួលសន្តតិ កម្មផ្នែកតាមចំណែកមត៌ កដែលច្បាប់បានកំណត់ រៀងៗខ្លួន។

ការបែងចែកមត៌កតាមការព្រមព្រៀងដោយបានដកBចេញ។
→ Cបានទទួលសន្តតិកម្មនូវអចលនវត្ថុLតែម្នាក់ឯង ហើយបានចុះបញ្ជី។

# 4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម

- ការបែងចែកមត៌កដែលត្រូវបានធ្វើឡើងដោយអវត្តមានសន្តតិជនមួយផ្នែក គឺត្រូវមោឃៈ ។
- សន្តតិជនដែលមិនបានចូលរួមក្នុងការបែងចែកមត៌ក អាចទាមទារឲ្យធ្វើបដិទានសន្តតិកម្មចំពោះអ្នកដែលបានទទួលមត៌ក （CC1301） ។

រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង



B

តើត្រូវដាក់ពាក្យសុំទាមទារឲ្យបែងចែកមត៌កសាជាថ្មីទេ （CC1270） ? ដោយសារតែការបែងចែកនោះត្រូវមោឃៈ ដូច្នេះហើយត្រូវដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបែងចែកមត៌កទេ? ឬក៏ត្រូវដាក់ពាក្យបណ្តឹងទាមទារឲ្យធ្វើបដិទានសន្តតិកម្ម? （CC1301） ?

រឿងក្តីរដ្ឋប្បវេណី

# 4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម

ខ្លឹមសារនៃដីកាសម្រេច ឬ ខ្លឹមសារនៃសាលក្រមដែលសន្តតិជនB ទាមទារនឹងមានភាពខុសគ្នាអាស្រ័យតាមកត្តាមួយចំនួន

- "ទាមទារនូវដីកាសម្រេចអំពីការបែងចែកមត៌ករបស់សន្តតិជនA"ជាអាទិ៍

→ ធ្វើការបែងចែកមត៌កម្តងទៀត(CC1270)

រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

- "បង្គាប់ឲ្យចុងចម្លើយC ធ្វើនីតិវិធីចុះបញ្ជីកែតម្រូវកម្មសិទ្ធិលើអចលនវត្ថុ L (ពត៌មានដែលកំណត់អំពី L) ដែលបានចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅថ្ងៃទី.....ខែ........ឆ្នាំ............លេខ......... មាន "កម្មសិទ្ធិករC" ទៅជា "ម្ចាស់កម្មសិទ្ធិអវិភាគC" ( 2ភាគ3) "ម្ចាស់កម្មសិទ្ធិអវិភាគ B (1ភាគ3) ដោយមូលហេតុភាន់ច្រឡំ" ជាអាទិ៍។

→ ការទាមទារឲ្យធ្វើបដិទានសន្តតិកម្ម (CC1301)

រឿងក្តីរដ្ឋប្បវេណី

# 4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម

• "បញ្ជាក់ថា ការបែងចែកមត៌ករបស់មតកជនAតាមការព្រមព្រៀងចុះថ្ងៃទី.....ខែ....ឆ្នាំ.......គឺមោឃៈ។"

→ បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបែងចែកមត៌កតាមការព្រមព្រៀង

រឿងក្ដីរដ្ឋប្បវេណី

※ ត្រូវបានប្រើប្រាស់ក្នុងករណីដែលមានភាពចាំបាច់ក្នុងការសម្រេចអំពីការវិនិច្ឆ័យលើអាជ្ញាអស់ជំនុំ (CCP194) ចំពោះ សុពលភាព ឬ មោឃភាពនៃការបែងចែកមត៌កតាមការព្រមព្រៀងដែលត្រូវបានធ្វើឡើងរួចហើយ។

→ក្រោយពីនោះ ចាំបាច់ត្រូវធ្វើការបែងចែកមត៌កសាជាថ្មី (CC1270)

# 4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម

“ឧទាហរណ៍អំពីបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបែងចែកមត៌កតាមការព្រមព្រៀង”




មត៌ក : មានតែអចលនវត្ថុLប៉ុណ្ណោះ



B

ក្រោយពីការបែងចែកមត៌កតាមការព្រមព្រៀងរួចមក ទើបដឹងថា C បានលាក់លុយចំនួន 1,000,000$ដែលAបានផ្ញើទុក។ ការបែងចែកមត៌កតាមការព្រមព្រៀងនេះគឺមោឃៈ។

តាមរយៈការបែងចែកមត៌កដោយការព្រមព្រៀងបានសម្រេចដោយខ្លឹមសារថា C នឹងទទួលសន្តតិកម្មនូវអចលនវត្ថុL ហើយCទទួលបានការចុះបញ្ជីលើL ។

# 4 សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តិកម្ម

“ឧទាហរណ៍អំពីបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបែងចែកមត៌កតាមការព្រមព្រៀង”




※ ចាំបាច់ត្រូវមានវត្តមានសហសន្តតិជនទាំងអស់ធ្វើជាភាគី (សហបណ្ដឹងចាំបាច់ដោយពិត（CCP41））

# Fin.

“ឯកសារយោង”

**The Legal and Judicial Development Project (Phase V)**

https://www.jica.go.jp/project/english/cambodia/025/materials/index.html